# “សរនាគបាស” ក្នុងល្ខោនស្បែកធំខ្មែរ

នាសម័យបុរាណ ប្រជាជនខ្មែររស់នៅក្នុងជីវិតមួយដែលមានពេលទំនេរច្រើនបន្ទាប់ពីការធ្វើស្រែចម្ការនិងអាចមានពេលវេលាគ្រប់គ្រាន់ ក្នុងការរៀបចំប្រារព្ធពិធីនិងបុណ្យទានដែលមានឫសគល់ក្នុងសាសនា ប្រពៃណី និងទំនៀមទម្លាប់របស់គេ។ សិល្បករល្ខោនស្បែកធំខ្មែរ បានបង្កើតសាច់រឿងវែងៗនិងមានខ្លឹមសារ ដូចដែលរឿងរាមកេរ្តិ៍ទាំងមូលត្រូវបានគេបែងចែកជាប្រាំពីរភាគឬឈុត ហើយភាគឬឈុតនីមួយៗត្រូវបានសម្តែងពេញមួយយប់ ជាបន្តបន្ទាប់ក្នុងរយៈពេលប្រាំពីរយប់។[១]

កាលនៅពីក្មេង ខ្ញុំបានទស្សនាសិល្បៈនេះសម្តែងនៅច្រើនកន្លែង នៅស្រុកកំណើតនិងនៅភ្នំពេញ ក្នុងព្រះរាជពិធីបុណ្យតាំងតុ ក្នុងបរិវេណពិពណ៌នៅខាងក្នុងនិងខាងមុខព្រះបរមរាជវាំង។ សិល្បៈទស្សនីយភាពជាច្រើន ត្រូវបានគេសម្តែងពេញមួយយប់ ចាប់ពីពេលព្រលប់រហូតដល់ពេលទៀបភ្លឺ រួមមានល្ខោនព្រះរាជទ្រព្យ ល្ខោនខោល ល្ខោនយីកេ ល្ខោនបាសាក់ ល្ខោនស្បែកតូច និងល្ខោនស្បែកធំ ជាដើម។

ភាគទាំងប្រាំពីររបស់ក្រុមល្ខោនស្បែកធំសាលាកន្សែង ខេត្តសៀមរាប ត្រូវបានគេបែងចែកជាគម្រោងទៅតាមដំណើររឿង ដូចខាងក្រោម៖ ឈុតទី១៖ ព្រះរាមកច្ឆល់, ឈុតទី២៖ បញ្ចកាយបណ្តែតទឹក, ឈុតទី៣៖ សរនាគបាស, ឈុតទី៤៖ ចម្បាំងកំប៉ាន់និងហនុមាន, ឈុតទី៥៖ សរព្រហ្មាស្ត្រ, ឈុតទី៦៖ ផ្តាំមឿងសុក្កចារ, និងឈុតទី៧៖ ផ្តាំមឿងឥន្ទជិត។ ក្នុងការសម្តែងល្ខោនស្បែកធំរបស់ក្រុមសាលាកន្សែង រឿងរាមកេរ្តិ៍ចាប់ផ្តើមជាមួយនឹងការកសាងផ្លូវកាត់ទឹកទៅក្រុងលង្កា និងបញ្ចប់ដោយមរណភាពរបស់ឥន្ទជិត។ ភាពទាំងស្រុងនៃរឿងទាំងប្រាំពីរភាគ ក្នុងការសម្តែងល្ខោនស្បែកធំនេះ ត្រូវបានចងក្រងទុកជាឯកសារសោតទស្សន៍ទាំងស្រុងពេញលេញ ដោយសារមន្ទីរជាតិផ្នែកជាតិពន្ធុវិទ្យា នាទីក្រុងអូសាកា ប្រទេសជប៉ុន សម្រាប់ការស្រាវជ្រាវនិងសិក្សាបន្តទៅអនាគត។

---

[១] Brunet 1974: 3

អត្ថបទ៖ "សរនាគបាស" ក្នុងល្ខោនស្បែកធំខ្មែរ

ក្នុងអត្ថបទនេះ នឹងលើកយកឈុតទី៣ «សរនាកបាស» ក្នុងដំណើររឿងរាមកេរ្តិ៍ ដែលជាឈុតមួយសម្តែងក្នុងល្ខោនស្បែកធំមកធ្វើការបរិយាយត្រួសៗ។ ត្រង់ឈុតទី៣ «សរនាកបាស»នេះ គឺបង្ហាញពីឈុតវិរុលមុខកុមារ ឥន្ទជិត ដែលពួននៅស្រទាប់មេឃ លួចផ្ទេង «សរនាគបាស» មកត្រូវ ព្រះលក្ស្មណ៍។ ខាងក្រោមនេះ នឹងបរិយាយពីសាច់រឿងសង្ខេបក្នុងឈុតទី៣ «សរនាកបាស» នៃរឿងរាមកេរ្តិ៍ដែលជានិច្ចជាកាលឃើញសម្តែងក្នុងល្ខោនស្បែកធំ៖

ព្រះរាម បានត្រាស់ប្រើ ជម្ពូពាន ឱ្យទៅបំបែកពិធីដែល ឥន្ទជិត បានទៅតាំងនៅក្នុងដើម នរូធ័នតិ។ ជម្ពូពាន បានប្រែកាឡាជាខ្លាឃ្មុំហើយសម្តែងឫទ្ធិទៅបំបែកពិធីរបស់ ឥន្ទជិត។ ឥន្ទជិត មានសេចក្តីក្រេវក្រោធយ៉ាងខ្លាំងដោយខ្លួនមិនអាចតាំងពិធីបានសម្រេច។ ឥន្ទជិត ក៏នាំពលសេនាឡើងទៅថ្វាយបង្គំគាល់ ក្រុងពពណ៍ ជាព្រះវរបិតា នាក្រុងលង្កា សូមឱ្យព្រះវរបិតាទ្រង់ត្រាស់បញ្ជាឱ្យ វិរុលមុខកុមារ ទៅជាមួយដើម្បីធ្វើសង្គ្រាមជាមួយព្រះរាម។

ទៅដល់សមរភូមិ ឥន្ទជិត បានបញ្ជាឱ្យ វិរុលមុខកុមារ ប្រែកាឡាជាអង្គ ឥន្ទជិត ហើយផ្តែផ្តាំ វិរុលមុខកុមារ ថា ចូរអ្នករង់ចាំធ្វើសង្គ្រាមជាមួយទ័ពរបស់ព្រះរាម។ ផ្តែផ្តាំរួចហើយ ឥន្ទជិត ក៏ហោះទៅពួននៅស្រទាប់មេឃ។

នៅវេលាម៉ោង៤ទៀបភ្លឺ ស្រាប់តែឮសូរសន្ទឹកស្រែកហ៊ោកញ្ជ្រៀវនៃទ័ពក្រុងមារ។ ព្រះរាម ទ្រង់បានសួរទៅ ពិភេក ហោរាថា អង្គអញបានឮសូរសន្ទឹកស្រែកហ៊ោកញ្ជ្រៀវនៅសមរភូមិ តើជាទ័ពអ្នកណា?។ ពិភេក ទូលថា គឺជាទ័ពរបស់ ឥន្ទជិត។ ដូច្នេះ សូមព្រះអង្គ ទ្រង់ត្រាស់ប្រើឱ្យ ស្រីលក្ស្មណ៍ អនុជាលើកទ័ពទៅតទល់ជាមួយទ័ព ឥន្ទជិត។ ព្រះលក្ស្មណ៍ និង ហនុមាន ព្រមទាំង ពិភេក បានលើកទ័ពទៅធ្វើសង្គ្រាមជាមួយ ឥន្ទ្រជិត។

ពេលជាប់ដៃគ្នាជាមួយ វិរុលមុខកុមារ ឥន្ទជិត ដែលពួននៅស្រទាប់មេឃក៏លួចផ្ទេង «សរនាគបាស» មកត្រូវ ព្រះលក្ស្មណ៍ ហនុមាន ព្រមទាំងពួកពលសកលយោធា នៅ

អត្ថបទដោយ៖

សល់តែ ពិភេក មិនបានត្រូវ សរនាគបាស នឹងគេ។ ពិភេក ក៏បានរត់ទៅទូល ព្រះរាម ថា ព្រះលក្ស្មណ៍ ហនុមាន ព្រមទាំងសេនាទាំងអស់បានត្រូវ សរនាគបាស ត្រូវនាគរុំជិតអស់ហើយ។ ដូច្នេះ សូម ព្រះរាម ផ្ញើសរទៅ ក្រុងសិម្ពលីគ្រុឌ ដែលជាព្រះធម៌បិតាដើម្បីឱ្យទ្រង់មកជួយយកអាសារ។ ព្រះរាម ក៏បានផ្ញើសរទៅស្ថានសិម្ពលីគ្រុឌ។ ស្តេចគ្រុឌ លុះបានទទួលសរដែលនាំសារហើយ ក៏ហោះហោះពីស្ថានសិម្ពលីមកឆាបឆក់ហ្វូងនាគដែលរឹតរួត ព្រះលក្ស្មណ៍ ហនុមាន និងសេនាទាំងអស់បានរួចរស់ជិវិត។ បន្ទាប់មក ព្រះរាម ក៏នាំព្រះលក្ស្មណ៍ ហនុមាន ពិភេក ព្រមទាំងពួកពលសកលយោធាទាំងអស់វិលចូលទៅព្រះនគរ ស្រីអយុធ្យា វិញឱ្យបានដូចព្រះរាជហឫទ័យ៕

## ឯកសារពិគ្រោះ


Brunet, Jacques. (1974). "Themes and Motifs of the Cambodian Ramayana in the Shadow Theatre," *Traditional Drama and Music of Southeast Asia*. Edited by Taib Mohd Osman. Kuala Lumpur: Dewan Bahasa Pustaka, 3-4.


អត្ថបទដោយ៖



ព្រះរាមផ្ទៃងសរ

ប្រភព៖ Borin Khmer Shadow Art Blogspot



ស្តេចគ្រុឌដោះសរនាគបាសចេញពីព្រះលក្ស្មណ៍

ប្រភព៖ Nhek Borin Khmer Shadow

អត្ថបទដោយ៖

# ស្ដេចគ្រុឌដោះសរនាគបាសចេញពីព្រះលក្ស ណ៍_by_Nhek_Borin_Khmer_Shadow

អត្ថបទដោយ៖